**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ០៧អនក្រ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៤អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- តាមសំណើរបស់រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់ និងគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ និងត្រួតពិនិត្យរាល់សកម្មភាព ចេញ-ចូល ព្រះរាជាណាចក្រកម្ពុជា របស់អ្នកដំណើរ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ ដើម្បីធានាឱ្យមានសន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់សង្គម នៅតំបន់ព្រំដែន និងក្នុងផ្ទៃប្រទេស កិច្ចការពារសុខុមាលភាព ជូនប្រជាពលរដ្ឋ និងចំណូលថវិកាជាតិ ។

## ជំពូកទី ២
## និយមន័យ

**មាត្រា ២ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ជាទីតាំងរបស់អង្គភាពចំរុះធ្វើការត្រួតពិនិត្យការ ចេញ-ចូលប្រទេស ជាលក្ខណៈអន្តរជាតិ និងការធ្វើសកម្មភាពរបស់អ្នកដំណើរ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅតាមអាកាសយានដ្ឋានអន្តរជាតិ និងកំពង់ផែអន្តរជាតិក្នុងផ្ទៃប្រទេស ដូចមានចែងក្នុងមាត្រា ៧ ជំពូកទី ៣ នៃអនុក្រឹត្យនេះ ។

**មានត្រា ៣ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ជាទីតាំងរបស់អង្គភាពចំរុះធ្វើការត្រួតពិនិត្យការចេញ-ចូលប្រទេស ជាលក្ខណៈអន្តរជាតិទ្វេភាគីតំបន់ព្រំដែន និងការធ្វើសកម្មភាពរបស់អ្នកដំណើរ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ដែលស្ថិតនៅលើខ្សែបន្ទាត់ព្រំដែន ដូចមានចែងក្នុងមាត្រា ៨ ជំពូកទី ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ៤ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេភាគី ជាទីតាំងរបស់អង្គភាពចំរុះធ្វើការត្រួតពិនិត្យការចេញ-ចូលប្រទេស ជាលក្ខណៈទ្វេភាគីលក្ខណៈតំបន់ព្រំដែន និងការធ្វើសកម្មភាពរបស់អ្នកដំណើរ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅច្រកទ្វារព្រំដែនទ្វេភាគី ដែលស្ថិតលើខ្សែបន្ទាត់ព្រំដែន ដូចមានចែងក្នុង

មាត្រា ៩ ជំពូកទី ៣ នៃអនុក្រឹត្យនេះ ស្របតាមកិច្ចព្រមព្រៀងទ្វេភាគី រវាងប្រទេសជាប់ព្រំដែនជាមួយព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន ជាទីតាំងរបស់អង្គភាពចំរុះ ធ្វើការត្រួតពិនិត្យការ ចេញ-ចូលប្រទេស ជាលក្ខណៈតំបន់ព្រំដែន និងការធ្វើសកម្មភាពរបស់អ្នកដំណើរ ដែលជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែននោះ មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅច្រកទ្វារព្រំដែន ដែលស្ថិតនៅលើខ្សែបន្ទាត់ព្រំដែន ស្របតាមកិច្ចព្រមព្រៀងរវាងប្រទេសជាប់ព្រំដែន ជាមួយព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា ១០ ជំពូក ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦ .-**

ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែសមុទ្រ គឺជាទីតាំងរបស់អង្គភាពចំរុះ ធ្វើការត្រួតពិនិត្យការចេញ-ចូលកំពង់ផែសមុទ្រ និងការធ្វើសកម្មភាពរបស់អ្នកដំណើរជាប្រជាពលរដ្ឋ នៃប្រទេសជាប់ព្រំដែន មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ នៅច្រកទ្វារកំពង់ផែសមុទ្រ ដែលស្ថិតនៅក្នុងប្រទេស ដូចមានចែងក្នុងមាត្រា ១១ ជំពូកទី ៣ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣

## ការកំណត់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារ

**មាត្រា ៧ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ :

- រាជធានីភ្នំពេញ : អាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង និងកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ
- ក្រុងព្រះសីហនុ : កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ
- ខេត្តសៀមរាប : អាកាសយានដ្ឋានសៀមរាប ។

**មាត្រា ៨ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារព្រំដែនអន្តរជាតិ :

- ខេត្តស្វាយរៀង : បាវិត
- ខេត្តកណ្តាល-ព្រៃវែង : ក្អមសំណរ-កោះរកា
- ខេត្តតាកែវ : ភ្នំដិន

- ខេត្តកោះកុង : ចាំយាម
- ខេត្តបន្ទាយមានជ័យ : ប៉ោយប៉ែត
- ខេត្តស្ទឹងត្រែង : ដុងក្រឡ ។

**មាត្រា ៩ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេភាគី :

- ខេត្តរតនគិរី : អូរយ៉ាដាវ
- ខេត្តមណ្ឌលគិរី : ដាក់ដាំ
- ខេត្តព្រះវិហារ : ប្រាសាទព្រះវិហារ
- ខេត្តក្រចេះ : ស្នួល
- ខេត្តកំពង់ចាម : ត្រពាំងផ្លុង
- ខេត្តកំពត : ព្រែកចាក
- ខេត្តស្វាយរៀង : ព្រៃវល្លិ៍ ។

**មាត្រា ១០ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន :

- ខេត្តមណ្ឌលគិរី : ឡាប៉ាខេ
- ខេត្តក្រចេះ : ជ័យឃ្លាំង និងត្រពាំងស្រែ
- ខេត្តកំពង់ចាម : ចាន់មូល ដា និង ជាំក្រវៀន
- ខេត្តព្រៃវែង : ពាមមន្ទា និងកោះសំពៅ
- ខេត្តស្វាយរៀង : សំរោង បុសមន និងស្រែបារាំង
- ខេត្តកណ្ដាល : ជ្រៃធំ-ខ្នាតាំងយូ
- ខេត្តតាកែវ : បាក់ដៃ និងកំពង់ក្រសាំង
- ខេត្តកំពត : គន់ហាន់
- ខេត្តពោធិ៍សាត់ : ភ្នំប្ញស្សី ស្ពានជ័យជំនះ និងច្រកផ្លូវ ៥៦
- ខេត្តបន្ទាយមានជ័យ : បឹងត្រកួន និងមេឡៃ
- ខេត្តឧត្ដរមានជ័យ : អូរស្មាច់ ជាំប្ញសងាំ និងព្រះប្រឡាយ
- ខេត្តព្រះវិហារ : អានសេះ
- ខេត្តបាត់ដំបង : ភ្នំដី សូនស៊ុំ ច្រក ៤០០ ច្រក ២០៣ ពាមតា មានជ័យឲ្យរាំ ភ្នំព្រឹក ស្វាយចេក និងអូររំដួល

- ក្រុងប៉ៃលិន : ច្រកព្រំ ។

**មាត្រា ១១ .-**

ត្រូវបានកំណត់ជាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែសមុទ្រ :

- ខេត្តកំពត : កោះសេះ ត្រពាំងល្ពៅ និងទីរួមខេត្ត
- ទីក្រុងកែប : ទីក្រុងកែប
- ក្រុងព្រះសីហនុ : ទំនប់រលក និងស្ទឹងហាវ
- ខេត្តកោះកុង : បាក់ខ្លង ថ្នល់ រំស្រែអំបិល និងកោះស្ដេច ។

## ជំពូកទី ៤

## ការកំណត់ភូមិសាស្ត្រទីស្នាក់ការត្រួតពិនិត្យច្រកទ្វារ

**មាត្រា ១២ .-**

- ភូមិសាស្ត្រទីស្នាក់ការត្រួតពិនិត្យច្រកទ្វារគ្រប់ប្រភេទ គឺជាដែនធ្វើសកម្មភាពត្រួតពិនិត្យដោយមន្ត្រីភ្នាក់ងារមានសមត្ថកិច្ចនៃទីស្នាក់ការត្រួតពិនិត្យនីមួយៗ ។
- ទំហំទីតាំងនៃទីស្នាក់ការត្រួតពិនិត្យច្រកទ្វារនីមួយៗ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។
- ចំពោះទីស្នាក់ការត្រួតពិនិត្យអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង និងអាកាសយានដ្ឋានសៀមរាប ប្រកាសរួមនេះ ត្រូវមានការចូលរួមពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ។
- ចំពោះទីស្នាក់ការត្រួតពិនិត្យកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ និងក្រុងព្រះសីហនុ ប្រកាសរួមនេះ ត្រូវមានការចូលរួមពីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។
- ក្នុងករណីមានវត្តមាន អនុវរៈការការពារព្រំដែននៃក្រសួងការពារជាតិ ប្រកាសរួមនេះ ត្រូវមានការចូលរួមពីរដ្ឋមន្ត្រីក្រសួងការពារជាតិដែរ ។
- ទំហំទីតាំងជាក់ស្ដែងនៃភូមិសាស្ត្រទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី និងច្រកទ្វារតំបន់ព្រំដែន ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបន្ទាប់ពីមានការ ឯកភាពពីគណៈកម្មាធិការចំរុះកិច្ចការព្រំដែន ។

## ជំពូកទី ៥

## សមាសភាព

**មាត្រា ១៣ .-**

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ :

ក/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង :

១- មន្ត្រីអាជ្ញាធរអាកាសចរស៊ីវិល នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
ជាប្រធាន និងជំនួយការ ចំនួន ០២នាក់

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ
ជាអនុប្រធាន និងសហការី ចំនួន ៤៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ជាសមាជិក និងសហការី ចំនួន ៦៣នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ១៥នាក់ ។

ខ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ :

១- មន្ត្រីកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ នៃក្រសួងសាធារណការ និងដឹកជញ្ជូន
ជាប្រធាន និងជំនួយការ ចំនួន ០៣នាក់

២- មន្ត្រីនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ
ជាអនុប្រធាន និងសហការី ចំនួន ២៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ជាសមាជិក និងសហការី ចំនួន ៣០នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ១៤នាក់

៥- មន្ត្រីកាំសាប ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក និងសហការី ចំនួន ០២នាក់ ។

គ/- ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែអន្តរជាតិ ក្រុងព្រះសីហនុ :

១- មន្ត្រីកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ នៃក្រសួងសាធារណការ និងដឹកជញ្ជូន
ជាប្រធាន និងជំនួយការ ចំនួន ០៣នាក់

២- មន្ត្រីនគរបាលជាតិ នាយកដ្ឋានជនបរទេសនៃក្រសួងមហាផ្ទៃ
ជាអនុប្រធាន និងសហការី ចំនួន ៤៩នាក់

7

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ៤៧នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ២៩នាក់

៥- មន្ត្រីកាំសាបក្រសួងសាធារណការ និងដឹកជញ្ជូន

ជាសមាជិក និងសហការី ចំនួន ០២នាក់ ។

ឃ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានសៀមរាប :

១- មន្ត្រីអាជ្ញាធរអាកាសចរស៊ីវិល នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ជាប្រធាន និងជំនួយការ ចំនួន ០២នាក់

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេសនៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ២៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១០នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៣នាក់ ។

**មាត្រា ១៤ .-**

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ :

ក/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត :

១- អភិបាលខេត្តបន្ទាយមានជ័យ ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេសនៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ៣៦នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ១១នាក់ ។

ខ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិបាវិត :

១- អភិបាលខេត្តស្វាយរៀង ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ២៤នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៩នាក់ ។

គ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន :

១- អភិបាលខេត្តតាកែវ ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១៥នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៨នាក់ ។

ឃ/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម :

១- អភិបាលខេត្តកោះកុង ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១២នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៦នាក់ ។

ង/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិក្អមសំណរ-កោះរការ :

១- អភិបាលខេត្តកណ្ដាល ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ៣៩នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ២៤នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៩នាក់ ។

ច/-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិដុងក្រឡ :

១- អភិបាលខេត្តស្ទឹងត្រែង ដែលអាចតំណាងដោយប្រតិភូជាន់ខ្ពស់ ០១រូប ជាប្រធាន

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេសនៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ២៤នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១៥នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៦នាក់ ។

**មាត្រា ១៥ .-**

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេភាគី :

១- មន្ត្រីរដ្ឋបាលមានឋានៈស្មើនឹងប្រធានការិយាល័យនៃសាលា ខេត្ត-ក្រុង សាមី

ជាប្រធាន និងសហការី ចំនួន ០១នាក់

២- នាយនគបាលជាតិ ការិយាល័យជនបរទេស នៃស្នងការនគរបាល ខេត្ត-ក្រុង សាមី

ជាអនុប្រធាន និងសហការី ចំនួន ២៤នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួនពី ០៣ ទៅ ២៩នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៧នាក់ ។

ដោយឡែកនៅច្រកទ្វារប្រាសាទព្រះវិហារ :

១- មន្ត្រីរដ្ឋបាលមានឋានៈស្មើនឹងប្រធានការិយាល័យនៃសាលាខេត្តព្រះវិហារ

ជាប្រធាន និងសហការី ចំនួន ០៣នាក់

២- នាយនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ

ជាអនុប្រធាន និងសហការី ចំនួន ២៤នាក់

៣- មន្ត្រីក្រសួងទេសចរណ៍ ជាសមាជិក និងសហការី ចំនួន ១២នាក់ ។

**មាត្រា ១៦ .-**

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន :

១- មន្ត្រីរដ្ឋបាលមានឋានៈស្មើនឹងប្រធានការិយាល័យនៃសាលា ខេត្ត-ក្រុង សាមី

ជាប្រធាន និងសហការី ចំនួន ០១នាក់

២- នាយនគរបាលជាតិ នាយកដ្ឋាននគរបាលការពារព្រំដែនគោក

ជាអនុប្រធាន និងសហការី ចំនួន ២៤នាក់

៣- មន្ត្រីឈ្មួយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួនពី ០៤ ទៅ ៣៧នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៩នាក់ ។

មាត្រា ១៧ .-

នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារកំពង់ផែសមុទ្រ :

១- មន្ត្រីរដ្ឋបាលមានឋានៈស្មើនឹងប្រធានការិយាល័យនៃសាលា ខេត្ត-ក្រុង សាមី

ជាប្រធាន និងសហការី ចំនួន ០១នាក់

២- នាយនគរបាលជាតិ ការិយាល័យជនបរទេស នៃស្នងការដ្ឋាននគរបាល ខេត្ត-ក្រុង

ជាអនុប្រធាន និងសហការី ចំនួន ២៥នាក់

៣- មន្ត្រីគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជាសមាជិក និងសហការី ចំនួន ១២នាក់

៤- មន្ត្រីកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ជាសមាជិក និងសហការី ចំនួន ០៥នាក់ ។

ដោយឡែកនៅទីស្នាក់ការត្រួតពិនិត្យកំពង់ផែសមុទ្រ កោះសេះ នាយនគរបាលជាតិ នាយកដ្ឋាន-នគរបាលព្រំដែនទឹក ជាអនុប្រធាន និងសហការី ចំនួន ១២នាក់ ។

## ជំពូកទី ៦

## ភារកិច្ច

មាត្រា ១៨ .-

ប្រធានទីស្នាក់ការត្រួតពិនិត្យ មានភារកិច្ច :

- ធ្វើជាអធិបតី ក្នុងសម័យប្រជុំនានារបស់ទីស្នាក់ការត្រួតពិនិត្យ
- ដឹកនាំកិច្ចការ រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ពេលប្រជុំ
- ធានាឱ្យមានកិច្ចប្រជុំរួមនៃគ្រប់តំណាងមានសមត្ថកិច្ច នៃទីស្នាក់ការត្រួតពិនិត្យ យ៉ាងហោចណាស់ឱ្យបានមួយដងក្នុងមួយខែ
- ធានាដឹកនាំផ្ទាល់ គ្រប់អង្គភាពចំណុះទីស្នាក់ការត្រួតពិនិត្យ ឱ្យដំណើរការបានត្រឹមត្រូវ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធវិធាន និងបទបញ្ជាផ្ទៃក្នុងនៃទីស្នាក់ការត្រួតពិនិត្យ
- ដឹកនាំកិច្ចការថែរក្សាការពារអធិបតេយ្យភាព បូរណភាពទឹកដី
- ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម

- សំរបសំរួលការងារក្នុងទីស្នាក់ការត្រួតពិនិត្យឱ្យមានភាពរលូន
- ដឹកនាំការងាររបស់ទីស្នាក់ការត្រួតពិនិត្យ និងរាយការណ៍ រាល់សកម្មភាពការងាររបស់កងកំលាំងនគរបាលជាតិ មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ទៅក្រសួង ស្ថាប័នសាមី ក្នុងករណីបុគ្គលណា ឬអង្គភាពណាប្រព្រឹត្តបទល្មើស
- ដឹកនាំកិច្ចការ សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងប្រទេស និងសមត្ថកិច្ចពាក់ព័ន្ធនៃប្រទេសជាប់ព្រំដែន ដើម្បីធានារក្សាការអនុវត្តន៍ត្រឹមត្រូវតាមកិច្ចព្រមព្រៀង និងច្បាប់របស់ប្រទេសនីមួយៗ
- ដឹកនាំ និងគ្រប់គ្រងការសាងសង់ជួសជុល និងរក្សាទីស្នាក់ការត្រួតពិនិត្យរួមមួយឱ្យបានរឹងមាំល្អ សមស្របតាមសំណង់វប្បធម៌ជាតិ ធានាបានការលើកតំកើងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា និងប្រសិទ្ធភាពការងារដោយសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីចៀសវាងឱ្យបាននូវការលំបាករបស់អ្នកឆ្លងកាត់
- ធានាឱ្យមានកន្លែងត្រួតពិនិត្យតែមួយរួមគ្នា
- ធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ ផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័ន សាមី តាមរយៈអភិបាល ខេត្ត-ក្រុង សាមី ។

**មាត្រា ១៩ .-**

មន្ត្រីនគរបាលជាតិ នៅច្រកទ្វារ មានភារកិច្ចៈ

- ត្រួតពិនិត្យអ្នកដំណើរ ចេញ-ចូលប្រទេស និងចេញ-ចូលតំបន់ព្រំដែនទាំងសញ្ជាតិបរទេស និងសញ្ជាតិខ្មែរ
- សហការត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ ដែល ចេញ-ចូល ព្រះរាជាណាចក្រកម្ពុជា សំដៅរកឃើញ និងបង្ក្រាបទាន់ពេលវេលា បទល្មើសឆ្លងដែន ការរត់ពន្ធ ជួញដូរមនុស្សខុសច្បាប់ ជួញដូរស្ត្រី និងកុមារ ការធ្វើចរាចររូបិយវត្ថុក្លែងក្លាយ ការជួញដូរគ្រឿងញៀន វត្ថុបុរាណ ការដឹកជញ្ជូន និងការជួញដូរ ការប្រើប្រាស់អាវុធជាតិផ្ទុះ និងបរិក្ខារសិកខុសច្បាប់ និងបទល្មើសផ្សេងៗទៀត ដើម្បីរក្សាសន្តិសុខ សុវត្ថិភាពសណ្តាប់ធ្នាប់សង្គម
- ត្រួតពិនិត្យ និងថែរក្សាស្លាកសញ្ញាព្រំដែន នៃខ្សែបន្ទាត់ព្រំដែន ដែលស្ថិតក្នុងភូមិសាស្ត្រច្រកទ្វារនីមួយៗ
- ចាត់វិធានការរក្សា សន្តិសុខ សណ្តាប់ធ្នាប់ ក្នុងភូមិសាស្ត្រច្រកទ្វារ ហើយក្នុងករណីចាំបាច់ត្រូវសហការ និងសុំអន្តរាគមន៍ពីអាជ្ញាធរដែនដីដែលពាក់ព័ន្ធ

- ដោយឡែកកំលាំងនគរបាលជាតិ នាយកដ្ឋានជនបរទេស ដែលបំពេញភារកិច្ចនៅច្រកទ្វារកំពង់ផែអន្តរជាតិរាជធានីភ្នំពេញ ត្រូវចាត់វិធានការអមការពារនាវា ពីចំណុចកណ្តាលមកកំពង់ផែ ។

**មាត្រា ២០ .-**

ភ្នាក់ងារគយ និរដ្ឋាករ មានភារកិច្ច :

- គ្រប់គ្រងត្រួតពិនិត្យ និងប្រមូលពន្ធ អាករ ព្រមទាំងកំរៃនានា លើទំនិញ និងមធ្យោបាយដឹកជញ្ជូននាំចេញ នាំចូលគ្រប់ប្រភេទ រួមទាំងឥវ៉ាន់អ្នកដំណើរ កញ្ចប់ប្រៃសណីយ៍ រូបិយវត្ថុ លោហធាតុ ឬត្បូងថ្មមានតំលៃ ព្រមទាំងសារធាតុផ្សេងៗទៀត ដែលមានចែងក្នុងតារាងពន្ធគយ នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមនីតិវិធីគយ និងបទបញ្ញត្តិច្បាប់ ពាក់ព័ន្ធផ្សេងទៀតជាធរមាន ។
- បញ្ជាក់លទ្ធផលនៃការត្រួតពិនិត្យនៅលើប្រតិវេទន៍គយ ហើយក្នុងករណីរកឃើញបទល្មើសគយ ត្រូវធ្វើកំណត់ហេតុបទល្មើស និងចាត់ចែងឃាត់ ឬរក្សាទុកជាបណ្តោះអាសន្ននូវទំនិញ ឬមធ្យោបាយល្មើសនេះ រង់ចាំការសំរេចពីស្ថាប័នមានសមត្ថកិច្ច ។
- ក្នុងករណីយល់ថាចាំបាច់ ភ្នាក់ងារគយ និងរដ្ឋាករ ត្រូវស្នើសុំកិច្ចសហការពីអាជ្ញាធរ ឬ ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ក្នុងពេលចុះត្រួតពិនិត្យរកបទល្មើសគយនានា ។

**មាត្រា ២១ .-**

ភ្នាក់ងារកាំកុងត្រូលមានភារកិច្ច :

- ត្រួតពិនិត្យលើបរិមាណទំងន់ គុណភាព សភាពផលិតផលនៃទំនិញ នាំចេញ-នាំចូល និងចេញវិញ្ញាបនប័ត្របញ្ជាក់លើបរិមាណ គុណភាពទំនិញ និងសភាពផលិតផល នៃទំនិញ នាំចេញ-នាំចូល
- លើកវិធានការរាំងខ្ទប់ និងចាប់ឃាត់ទំនិញ នាំចេញ-នាំចូល ខូច ឬអន់គុណភាព និងបង្ក្រាបការក្លែងបន្លំ
- ប្រមូលប្រាក់កំរៃ ដែលបានមកពីការត្រួតពិនិត្យទំនិញនាំចេញ-នាំចូល បង់ចូលថវិការដ្ឋ ។

**មាត្រា ២២ .-**

ភ្នាក់ងារក្រសួងសាធារណការ និងដឹកជញ្ជូន មានភារកិច្ច :

- ពិនិត្យ និងសំរួលការស្នើសុំចូលចតនៅផែអន្តរជាតិរាជធានីភ្នំពេញ និងក្រុងព្រះសីហនុ សំរាប់នាវាដឹកទំនិញ និងនាវាទេសចរណ៍គ្រប់ប្រភេទ

- ត្រួតពិនិត្យកត់ត្រា និងធ្វើរបាយការណ៍ជាប្រចាំ អំពីបរិមាណនាវា បរិមាណទំនិញឆ្លងកាត់ ការខូចខាត ឬ បាត់បង់ ទំនិញសំរាប់ការនាំចេញ-នាំចូល ព្រះរាជាណាចក្រកម្ពុជា
- សំរួលការស្នើសុំ កណ្ណធាការ សំរាប់នាំនាវាចូល ចេញពីកំពង់ផែអន្តរជាតិ ។

មាត្រា ២៣ .-

- ក្រុមគយ និងរដ្ឋាករចល័ត ដែលស្ថិតក្រោមការដឹកនាំផ្ទាល់របស់នាយកទីចាត់ការគយ និងរដ្ឋាករ មានភារកិច្ចធ្វើការស្រាវជ្រាវ និងបង្ក្រាបអំពើរត់គេចពន្ធ ពីច្រកទ្វារព្រំដែន ចូលមកផ្ទៃក្នុងប្រទេស ។
- ក្រុមគយ និងរដ្ឋាករចល័តនេះ អាចចេញធ្វើប្រតិបត្តិការឃាត់មធ្យោបាយដឹកទំនិញបាន ក្នុងពេលណាដែលទទួលពត៌មានថា មធ្យោបាយដឹកទំនិញនោះ កំពុងប្រព្រឹត្តអំពើរត់គេចពន្ធ ពីព្រំដែនចូលមកផ្ទៃក្នុងប្រទេស និងមានបញ្ជាបេសកកម្មពីនាយកទីចាត់ការគយ និងរដ្ឋាករ តាមករណីជាក់ស្តែងនីមួយៗ ។ មិនអនុញ្ញាតឱ្យក្រុមគយ និងរដ្ឋាករចល័តនេះ ធ្វើសកម្មភាពបែបអនាធិបតេយ្យឡើយ ។

មាត្រា ២៤ .-

មន្ត្រីភ្នាក់ងារ មានសមត្ថកិច្ចគ្រប់ជំនាញ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនក្រសួង ស្ថាប័នសាមី និងប្រធានទីស្នាក់ការ ។

មាត្រា ២៥ .-

មន្ត្រីភ្នាក់ងារមានសមត្ថកិច្ចទាំងអស់នៅតាមទីស្នាក់ការត្រួតពិនិត្យ ត្រូវសហការធ្វើការត្រួតពិនិត្យស្របពេលជាមួយគ្នា តាមជំនាញ និងដោយឆាប់រហ័សតាមទំហំការងារ នៅកន្លែងតែមួយ ដោយហាមឃាត់មិនឱ្យមានការបើកផែកទំនិញលើសពីមួយដង សំរាប់រយៈពេលឆ្លងកាត់ច្រកទ្វារទាំងមូល ។ ក្នុងករណីកំលាំង ឬភ្នាក់ងារណា ពុំបានចូលរួមត្រួតពិនិត្យតាមការកំណត់របស់ប្រធានទីស្នាក់ត្រួតពិនិត្យទេនោះ គឺត្រូវចាត់ទុក ថាបានត្រួតពិនិត្យរួចហើយ ។

ការត្រួតពិនិត្យបែបបទ របស់មន្ត្រីមានសមត្ថកិច្ច លើនាវាអន្តរជាតិដែល ចេញ-ចូល ព្រះរាជាណាចក្រកម្ពុជា តាមច្រកសមុទ្រ ឬច្រកទន្លេមេគង្គ ត្រូវធ្វើតែម្តងគត់ពេលនាវាចូលដល់កំពង់ផែគោលដៅក្រុងព្រះសីហនុ ឬកំពង់ផែគោលដៅរាជធានីភ្នំពេញ ។ នៅច្រកទន្លេមេគង្គ ភ្នាក់ងារគយ និងរដ្ឋាករ និងមន្ត្រីនគរបាលច្រកទ្វារព្រំដែន អាចចាត់តាំងភ្នាក់ងារ និងមន្ត្រីអមនាវា ក្នុងករណីចាំបាច់ ។

ការឈប់សំចតរបស់នាវាអន្តរជាតិ នៅតាមទីតាំងចំណតផែផ្សេងទៀត ក្រៅតំបន់ភូមិសាស្ត្រកំពង់ផែដែលបានកំណត់ ត្រូវមានការអនុញ្ញាតជាមុន ពីប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិកំពង់ផែ ក្រុងព្រះសីហនុ ឬកំពង់ផែរាជធានីភ្នំពេញ ។

មាត្រា ២៦ .-

មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច នៅតាមទីស្នាក់ការត្រួតពិនិត្យ ត្រូវមានវត្តមានអនុវត្តភារកិច្ចរបស់ខ្លួនក្នុងទីស្នាក់ការតែមួយកន្លែងហើយធ្វើការនៅជាប់១ភ្នា ដើម្បីសំរួលការងារក្នុងការពេញបែបបទដល់អ្នកដំណើរ និងម្ចាស់ទំនិញឱ្យបានឆាប់ ។

មាត្រា ២៧ .-

ប្រធានភ្នាក់ងារ មានសមត្ថកិច្ចជំនាញនីមួយៗ ត្រូវបែងចែកវេនប្រចាំការ គិតទាំងថ្ងៃឈប់សំរាក ឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែងនៃទីស្នាក់ការ ត្រួតពិនិត្យរបស់ខ្លួន ដើម្បីធានានិរន្តរភាពការងារ ។

## ជំពូកទី ៧
## សមត្ថកិច្ចអាជ្ញាធរដែនដី

មាត្រា ២៨ .-

អភិបាល ខេត្ត-ក្រុង សាមី តំណាងឱ្យរាជរដ្ឋាភិបាល មានភារកិច្ច :

- ដាក់ចេញ និងត្រួតពិនិត្យការអនុវត្តនីតិវិធីបទបញ្ជាផ្ទៃក្នុងរបស់ទីស្នាក់ការត្រួតពិនិត្យ ដែលស្ថិតក្នុងដែនដីគ្រប់គ្រងរបស់ខ្លួន និងសំរបសំរួលដល់ការងារ ដើម្បីធ្វើឱ្យទីស្នាក់ការត្រួតពិនិត្យមានដំណើរការស្របច្បាប់ និងលិខិតបទបញ្ញត្តិជាធរមាន
- បង្ក្រាប និងលុបបំបាត់កំលាំងដែលបង្កើតទីស្នាក់ការត្រួតពិនិត្យអនាធិបតេយ្យ ក្នុងដែនដីគ្រប់គ្រងរបស់ខ្លួន
- ពិនិត្យ និងចុះហត្ថលេខា លើរបាយការណ៍របស់ទីស្នាក់កា/ត្រួតពិនិត្យ ដើម្បីផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី ៨
## អាណត្តិបំពេញការងារ

មាត្រា ២៩ .-

ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន ច្រកទ្វារកំពង់ផែសមុទ្រ និងប្រធានភ្នាក់ងារមានសមត្ថកិច្ចជំនាញ ត្រូវធ្វើការផ្លាស់ប្តូររយៈពេល០២ឆ្នាំម្តង ។

**មាត្រា ៣០ .-**

មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន ច្រកទ្វារកំពង់ផែសមុទ្រ ត្រូវធ្វើការផ្លាស់ប្តូរក្នុងរយៈពេល ០១ឆ្នាំម្តង ។

**មាត្រា ៣១ .-**

ប្រធានក្រសួង ស្ថាប័ន ជំនាញនីមួយៗ អាចធ្វើការផ្លាស់ប្តូរទៅតាមតម្រូវការចាំបាច់ ចំពោះមន្ត្រីដឹកនាំ និងមន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ដែលប្រចាំការនៅតាមទីស្នាក់ការត្រួតពិនិត្យនានានៅពេលណាក៏បាន ។

## ជំពូកទី ៩

## កំលាំងអន្តរាគមន៍

**មាត្រា ៣២ .-**

កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ កងនគរបាលជាតិ និងសមត្ថកិច្ចដទៃទៀត ដែលមានទីតាំងនៅជិតទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ ត្រូវចេញធ្វើអន្តរាគមន៍ ក្នុងករណីដែលមានសំណើសុំពីប្រធានទីស្នាក់ការត្រួតពិនិត្យ ។

**មាត្រា ៣៣ .-**

កំលាំងអន្តរាគមន៍ដែលមានចែងក្នុងមាត្រា ៣២ មិនត្រូវមានទីតាំង ឬបន្ទាយ និងមិនត្រូវធ្វើសកម្មភាពក្នុងភូមិសាស្ត្រច្រកទ្វាររបស់ទីស្នាក់ការត្រួតពិនិត្យទេ ក្នុងករណីគ្មានសំណូមពរពីប្រធានទីស្នាក់ការត្រួតពិនិត្យ ។

## ជំពូកទី ១០

## យន្តការឃ្លាំមើល

**មាត្រា ៣៤ .-**

បង្កើតយន្តការមួយដែលមានតំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន តំណាងក្រសួង ស្ថាប័ន និងតំណាងសាលា ខេត្ត-ក្រុង ពាក់ព័ន្ធ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីឃ្លាំមើលសកម្មភាព របស់ទីស្នាក់ការត្រួតពិនិត្យ និងរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

## ជំពូកទី ១១

## ទោសប្បញ្ញត្តិ

**មាត្រា ៣៥ .-**

មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ដែលរំលោភប្រើប្រាស់តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនបង្កឱ្យមានការលំបាកដល់អ្នកដំណើរ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងទំនិញគ្រប់ប្រភេទ ដោយគ្មានមូលហេតុស្របច្បាប់ ឬរំលោភសមត្ថកិច្ច ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៣៦ .-**

អាជ្ញាធរដែនដីណា ដែលមិនបានបំពេញភារកិច្ចក្នុងការលុបបំបាត់ឱ្យអស់ជាស្ថាពរនូវកន្លែងត្រួតពិនិត្យអនាធិបតេយ្យ ក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន នឹងត្រូវទទួលទណ្ឌកម្មស្របតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

## ជំពូកទី ១២

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៧ .-**

ទីស្នាក់ការត្រួតពិនិត្យត្រូវមានតែមួយកន្លែងរួមគ្នា សំរាប់ច្រកទ្វារមួយទាំងមូល ។ ក្នុងករណីពុំទាន់មានទីស្នាក់ការត្រួតពិនិត្យរួមតែមួយនេះនោះ មន្ត្រីភ្នាក់ងារមានសមត្ថកិច្ចទាំងអស់ ត្រូវធ្វើការនៅក្នុងទីស្នាក់ការគយ និងរដ្ឋាករ ជាបណ្តោះអាសន្ន រហូតទីស្នាក់ការត្រួតពិនិត្យរួម ត្រូវបានសាងសង់រួចជាស្ថាពរ ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

**មាត្រា ៣៨ .-**

អនុក្រឹត្យលេខ ៤៥អនក្រ.បក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៧ អនុក្រឹត្យលេខ ៤៩អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៧ លិខិតបញ្ជាលេខ ២២បជ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧ អនុក្រឹត្យលេខ ៣៦អនក្រ.បក ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៨ សេចក្តីសំរេចលេខ ១៨សសរ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងបទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៩ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ប្រចាំក្រុងកែប ប្រចាំក្រុងប៉ៃលិន និងអភិបាលគ្រប់ ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៩
- កាលប្បវត្តិ-ឯកសារ